ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០១៥ ដោយ អគ្គនាយកដ្ឋានពន្ធដារ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# កិច្ចប្រជុំបូកសរុបលទ្ធផលប្រមូលចំណូលពន្ធប្រចាំខែមករា ឆ្នាំ២០១៥

នាវេលាម៉ោង ០៨:៣០ នាទីព្រឹក ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៥ នៅអគ្គនាយកដ្ឋានពន្ធដារ មានរៀបចំកិច្ចប្រជុំបូកសរុបការងារសារពើពន្ធប្រចាំខែមករា ឆ្នាំ២០១៥ របស់អគ្គនាយកដ្ឋានពន្ធដារ ក្រោមអធិបតីភាពរបស់ឯកឧត្តមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ និងឯកឧត្តម **អ៊ុំ សីហា** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ ហើយមានការចូលរួមឯកឧត្តមលោកស្រីអគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ លោកប្រធាន-អនុប្រធាននាយកដ្ឋាន លោកប្រធាន-អនុប្រធានសាខាពន្ធដារខេត្ត-ខណ្ឌទាំងអស់ក្រោមចំណុះអគ្គនាយកដ្ឋានពន្ធដារ។



ជាកិច្ចចាប់ផ្តើមឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានសំដែងអំណរសារទរជាមួយថ្នាក់ដឹកនាំនិងមន្ត្រីរាជការពន្ធដារគ្រប់ជាន់ថ្នាក់អំពីលទ្ធផលការងារប្រមូលចំណូលពន្ធដារ ដែលសម្រេចបានប្រចាំខែមករា ឆ្នាំ២០១៥ និងជម្រុញការលើកទឹកចិត្តថ្នាក់ដឹកនាំគ្រប់អង្គភាពពន្ធដារ សមាជិកអង្គប្រជុំដែលជាតំណាងមន្ត្រីពន្ធដារទូទាំងប្រទេសឲ្យខិតខំជំនះការលំបាកនិងបញ្ហាប្រឈមនានា ខិតខំអនុវត្តភារកិច្ចប្រមូលចំណូលពន្ធគ្រប់ប្រភេទ ឲ្យបានសម្រេចតាមគោលដៅកំណត់ក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង បង្កើនការផ្តល់សេវាដល់អ្នកជាប់ពន្ធឲ្យបានប្រសើរ ផ្តល់ភាពងាយស្រួលដល់អ្នកជាប់ពន្ធទទួលសេវាងាយស្រួល ឆាប់រហ័សនៅគ្រប់ទីកន្លែង និងអនុវត្តវិធានការនានាសំដៅធ្វើឲ្យបានសម្រេចគោលដៅចំណូលឆ្នាំ២០១៥។

ក្នុងខែមករា ឆ្នាំ២០១៥នេះ អគ្គនាយកដ្ឋានពន្ធដារបានប្រមូលនិងបង់ប្រាក់ពន្ធចូលថវិកាជាតិបានចំនួន ៣៣៩ ១៨៥ លានរៀល (គិតជាដុល្លារប្រមាណ ៨៤,៨០ លានដុល្លារ) ស្មើនឹង ៧,៣% នៃផែនការ

កំណត់ដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។ ប្រសិនបើប្រៀបធៀបទៅនឹងចំណូលពន្ធប្រចាំខែមករា ឆ្នាំ២០១៤ ឃើញថា ការប្រមូលចំណូលពន្ធដារបង់ចូលថវិកាជាតិប្រចាំខែមករា ឆ្នាំ២០១៥ នេះ មានការកើនឡើងស្មើនឹង ២៧,២០%។

ក្នុងរយៈពេលដូចគ្នាឆ្នាំ២០១៤ និងឆ្នាំ២០១៥ ឃើញថា ក៏មានការកើនឡើងនូវចំណូលពន្ធតាមប្រភេទពន្ធសំខាន់ៗមួយចំនួន ដូចជា ពន្ធលើប្រាក់ចំណេញមានការកើនឡើងប្រមាណ ៣៩,៤% ពន្ធលើប្រាក់បៀវត្សមានការកើនឡើងប្រមាណ ៣០,៨% និង អាករពិសេសមានការកើនឡើងប្រមាណ ៣៩,២%។

បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាឆ្នាំ២០១៤ និងឆ្នាំ២០១៥ ចំណូលពន្ធតាមសកម្មភាពអាជីវកម្មមានការកើនឡើងស្ទើរតែទាំងអស់ ក្នុងនោះរួមមាន ÷ ផ្នែកផលិតភេសជ្ជៈកើនឡើងប្រមាណ ៥៦,៥% សេវាហិរញ្ញវត្ថុកើនឡើងប្រមាណ ៣៦,៩% ទូរគមនាគមន៍កើនឡើងប្រមាណ ៨៧,១% នីហរ៍ណអាហរ៍ណកើនឡើងប្រមាណ ១១,៤% ផលិតគ្រឿងប្រើប្រាស់កើនឡើងប្រមាណ ៤៤,៣% ផ្នែកសណ្ឋាគារនិងផ្ទះសំណាក់កើនឡើងប្រមាណ ៤៦,៩% លក់ផលិតផលតេលសិលាកើនឡើងប្រមាណ ៦,១% ផលិតសម្លៀកបំពាក់កើនឡើងប្រមាណ ៣៨,២%ផលិតថ្នាំជក់កើនឡើងប្រមាណ ៥០,៩% លក់សម្ភារៈការិយាល័យកើនឡើងប្រមាណ ២១,៨% លក់ភេសជ្ជៈកើនឡើងប្រមាណ ២២,៤% ផលិតគ្រឿងអេឡិចទ្រិចកើនឡើងប្រមាណ ១០០,៨% ផលិតយានយន្តកើនឡើងប្រមាណ ៣១៩,៤% ផលិតម្ហូបអាហារកើនឡើងប្រមាណ ៧៦,៣% ផ្នែកលក់គ្រឿងយន្តកើនឡើងប្រមាណ ៤១,៦% ផលិតគ្រឿងអេឡិចទ្រិចកើនឡើងប្រមាណ ១០០,៨% ផលិតគ្រឿងចក្រកើនឡើងប្រមាណ ៨៨,៣% ។

ក្នុងអង្គប្រជុំឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានផ្តោតលើចំណុចសំខាន់ៗមួយចំនួនដូចជា ១-ពិនិត្យនិងពិភាក្សាលើរបាយការណ៍លទ្ធផលប្រមូលចំណូលពន្ធប្រចាំខែរបស់នាយកដ្ឋាន និងសាខាពន្ធដារខេត្ត-ខណ្ឌ។ ២- ការត្រួតពិនិត្យការប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូននិងយានជំនិះគ្រប់ប្រភេទសម្រាប់ឆ្នាំ២០១៤។ ៣-ការប្រកាសបង់ពន្ធលើប្រាក់ចំណេញសម្រាប់ឆ្នាំ២០១៤។ ៤-ការប្រមូលពន្ធប៉ាតង់សម្រាប់ឆ្នាំ២០១៥ ។ ៤- ណែនាំនិងពិភាក្សាការចុះបញ្ជីសហគ្រាសតាមប្រព័ន្ធថ្មីនិងការធ្វើបច្ចុប្បន្នភាពសហគ្រាស។ ៥-បញ្ហាផ្សេងៗ។

ដើម្បីប្រមូលចំណូលបានគ្រប់តាមផែនការច្បាប់ និងដើម្បីធានាបាននូវភាពជឿទុកចិត្តផ្នែកថវិកាសម្រាប់បម្រើឲ្យកិច្ចការគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល និងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនោះ ជាទិសដៅអនុវត្តបន្ត អគ្គនាយកដ្ឋានពន្ធដារនឹងខិតខំអនុវត្តយ៉ាងម៉ឺងម៉ាត់ និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការបន្តជំរុញអនុវត្តឲ្យកាន់តែស៊ីជម្រៅថែមទៀតនូវគោលនយោបាយកែទម្រង់ដ៏មុតស្រួច និងការពង្រឹងអភិបាលកិច្ចល្អរបស់រាជរដ្ឋាភិបាល សំដៅបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ នៃសេវាសាធារណៈជូនប្រជាពលរដ្ឋ។ ជាមួយគ្នានេះដែរ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តអប់រំណែនាំ ពង្រឹងសមត្ថភាពជំនាញ និងទេព្យកោសល្យរបស់មន្ត្រីពន្ធដារ ក្នុងការអនុវត្តការងារប្រកបដោយវិជ្ជាជីវៈ មានការទទួលខុសត្រូវខ្ពស់ ដោយឈរលើមនសិការ ស្មារតីតម្កល់ផលប្រយោជន៍ជាតិ ជាចម្បង។

ទន្ទឹមនឹងនេះ នឹងបន្តលើកកម្ពស់និងបញ្ជ្រាបវប្បធម៌ពន្ធដារ បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីសារពើពន្ធក្នុងចំណោមធុរជន ដើម្បីធានាបាននូវបរិកាសធុរកិច្ច និងការប្រកួតប្រជែងដោយស្មើភាពគ្នា ពង្រឹងការប្រមូលចំណូលឲ្យអស់លទ្ធភាព ប្រកបដោយតម្លាភាព ប្រសិទ្ធភាព ស័ក្តិសិទ្ធិខ្ពស់ និងសមធម៌ ចំពោះគ្រប់ធុរជន។



ជាកិច្ចបញ្ចប់ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ បានវាយតម្លៃខ្ពស់ដល់គ្រប់អង្គភាពពន្ធដារ ដែលបានប្រឹងប្រែងខិតខំប្រមូលចំណូលមានការកើនឡើងគួរជាទីពេញចិត្ត និងផ្តល់អនុសាសន៍ណែនាំបន្ថែមដល់អស់លោកជាប្រធានអង្គភាពពន្ធដារគ្រប់លំដាប់ថ្នាក់និងមន្ត្រីពន្ធដារទាំងអស់ឲ្យខិតខំពង្រឹងការអនុវត្តច្បាប់ វិន័យការងារ និងក្រមសីលធម៌វិជ្ជាជីវៈមន្ត្រីពន្ធដារឲ្យបានល្អប្រសើរតាមរយៈការផ្តល់សេវាអ្នកជាប់ពន្ធប្រកបដោយប្រសិទ្ធភាព និងភាពទន់ភ្លន់ តែម៉ឺងម៉ាត់ ដោយគោរពច្បាប់និងបទប្បញ្ញត្តិជាគោល ធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធរីករាយក្នុងកិច្ចសហការបង់ពន្ធជូនរដ្ឋ និងកិច្ចពង្រឹងរដ្ឋបាលសារពើពន្ធដើម្បីការប្រមូលពន្ធឲ្យកាន់តែទទួលបានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីឈានទៅសម្រេចបានតាមផែនការក្នុងច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥។

**អគ្គនាយកដ្ឋានពន្ធដារ**